# នាងកឋា —វីដេអូពីការនាំខ្លួនមកឆ្លើយនៅមុខតុលាការ

## ការយល់អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក
## នៅកន្លែងធ្វើការចោទប្រកាន់

Khmer

## ភាគទី 1 – នៅក្នុងបន្ទប់កាត់ក្តីធ្វើការចោទប្រកាន់ដែលមិនមានមនុស្ស

**ស៊ូសាន (SUSAN)** ៖ សួរស្តី! នាងខ្ញុំឈ្មោះ ស៊ូសាន គិមបល (Susan Kimball) ។

វីដេអូនេះ អាចជួយអ្នកឲ្យយល់បានអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក នៅក្នុងសវនាការចោទប្រកាន់ទោសក្នុងថ្ងៃនេះ ។ អ្នកក៏នឹងបានរៀនផងដែរនូវជំនួយបន្ថែម ដែលតុលាការអាចផ្តល់ជូនអ្នក ដោយមិនគិតថ្លៃ ដោយបូករួមទាំងសិទ្ធិពិភាក្សាជាមួយមេធាវី ។

បើអ្នកមានបញ្ហាពិបាកនិយាយ ឬពិបាកយល់ភាសាអង់គ្លេស ហើយត្រូវការអ្នកបកប្រែ សូមប្រាប់ឲ្យក្រឡាបញ្ជីបានដឹង ។

បើអ្នកមិនបានកើតនៅលើទឹកដីអាមេរិក ឬបើអ្នកមិនមែនជាពលរដ្ឋអាមេរិកាំងទេនោះ គឺអ្នកត្រូវប្រាប់មេធាវីរបស់អ្នកឲ្យបានដឹង ឬក៏អាចប្រាប់ឲ្យចៅក្រមបានដឹង បើអ្នកមិនមានមេធាវីជាតំណាងទេនោះ នៅមុនពេលចូលសារភាពកំហុស ឬមិនព្រមផ្តល់ចម្លើយ ។ ហើយបើអ្នក ដឹងច្បាស់អំពីស្ថានភាពផ្លូវច្បាប់របស់ខ្លួន ឬក៏អ្នកត្រូវការព័ត៌មានបន្ថែម អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក អ្នកត្រូវទាក់ទងជាមួយនឹងគម្រោងតស៊ូមតិផ្លូវច្បាប់សម្រាប់ជនអន្តោប្រវេសន៍ (Immigrant Legal Advocacy Project) នៅមុនពេលចូលសារភាពកំហុស ឬមិនព្រមផ្តល់ចម្លើយ ។ ហើយបើអ្នកមានអារម្មណ៍ថា ខ្លួនមិនអាចចូលរួមបានពេញលេញចំពោះសវនាការក្នុងថ្ងៃនេះទេ ដោយសារអ្នកមានពិការភាពចំពោះការនិយាយ ឬបាត់បង់សមត្ថភាពក្នុងការស្តាប់ ឬអ្នកត្រូវការភាពសម្រួល ដោយសារតែស្ថានភាពសុខភាព គឺអ្នកត្រូវប្រាប់ក្រឡាបញ្ជី ឬប្រធានតុលាការឲ្យបានដឹង ។

បន្ទប់កាត់ក្តីទាំងអស់ នៅក្នុងរដ្ឋ Maine គឺសុទ្ធតែមានបំពាក់ឧបករណ៍ពិសេស សម្រាប់ជួយអ្នកអាចស្តាប់ឮបានច្បាស់ ហើយឧបករណ៍ទាំងអស់នោះ ងាយស្រួលក្នុងការប្រើប្រាស់ណាស់ ។

មកជាមួយនឹងយើងខ្ញុំក្នុងថ្ងៃនេះ ដែលនឹងនិយាយសង្កត់ធ្ងន់លើដំណើរការចោទប្រកាន់ទោស គឺលោកចៅក្រម វ៉េន ឌូក្លាស់ (Wayne Douglas) នៃតុលាការជាន់ខ្ពស់របស់រដ្ឋ Maine ។ ចៅក្រមឌូក្លាស់ (Douglas) សូមថ្លែងអំណរគុណជាខ្លាំងដែលបានមកចូលរួមក្នុងថ្ងៃនេះ។

**តុលាការ** ៖ ខ្ញុំមានសេចក្តីរីករាយណាស់ ដែលបានមកទីនេះ ក្នុងថ្ងៃនេះ ។

**ស៊ូសាន (SUSAN)** ៖ តើគេអាចធ្វើអ្វី បើពួកគេមានសំណួរអំពីការចោទប្រកាន់ចំពោះពួកគេ ឬមានសំណួរអំពី ដំណើរការចោទប្រកាន់ទោស?

**តុលាការ** ៖ បើអ្នកមានសំណួរអំពីការចោទប្រកាន់ទោស ដែលអ្នកកំពុងប្រឈម សំណួរអំពីសិទ្ធិរបស់អ្នក សំណួរអំពីថាតើ ត្រូវទទួលការផ្តល់ជូនពីរដ្ឋ ដើម្បីដោះស្រាយសំណុំរឿងរបស់អ្នកក្នុងថ្ងៃនេះ ឬបើអ្នកមានសំណួរអំពីដំណើរការទូទៅរបស់តុលាការ គឺយើងនឹងមានមេធាវី មានវត្តមានចាំពិភាក្សាជាមួយអ្នកក្នុងថ្ងៃនេះ ដោយមិនអស់ប្រាក់ ។ បើអ្នកចង់ពិភាក្សាជាមួយនឹងមេធាវីរូបនេះ មុនពេលចូលកន្លែងផ្តល់ចម្លើយ សូមប្រាប់ចៅក្រមឲ្យបានដឹង នៅពេលគេហៅសំណុំរឿងរបស់អ្នក ។ ចៅក្រមនឹងផ្តល់ពេលឲ្យអ្នកពិភាក្សាជាមួយនឹងមេធាវី ។

**ស៊ូសាន (SUSAN)** ៖ លោកបាននិយាយពាក្យថាសិទ្ធិ ។ ចំពោះសំណុំរឿងឧក្រិដ្ឋកម្ម តើជនជាប់ចោទមានសិទ្ធិអ្វីខ្លះ?

**តុលាការ** ៖ ជនណាមួយដែលត្រូវគេចោទប្រកាន់ពីបទឧក្រិដ្ឋ រូបគេមានសិទ្ធិសំខាន់ដែលមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញ ។

ទីមួយ បើគេចោទប្រកាន់អ្នកអំពីបទឧក្រិដ្ឋ គឺអ្នកនៅត្រូវបានសន្មត់ថាជាជនបរិសុទ្ធមិនមានទោសតាមការចោទប្រកាន់ឡើយ ។ បើអ្នកមិនសារភាពទទួលកំហុស ឬមិនព្រមផ្តល់ចម្លើយ គឺគេមិនអាចកាត់ទោសអ្នកជាជនឧក្រិដ្ឋឡើយ បើនៅមិនទាន់បានកាត់ក្តី ហើយរដ្ឋនៅមិនទាន់បានបង្ហាញភស្តុតាង ហួសពីការសង្ស័យថាអ្នកបានប្រព្រឹត្តបទឧក្រិដ្ឋមែននោះ ។ ត្រង់នេះ គឺមានន័យថា នៅក្នុងពេលកាត់ក្តី រដ្ឋត្រូវតែបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញឲ្យគណវិនិច្ឆ័យ ឬចៅក្រមអាចជឿថា ការចោទប្រកាន់នេះ គឺស្ទើរតែពិតប្រាកដមួយរយភាគរយទៅហើយ ។

ទីពីរ គឺអ្នកមានសិទ្ធិមិននិយាយអ្វីទាំងអស់ ។ គឺជាប្រការសំខាន់ដែលអ្នកត្រូវយល់ឲ្យបានថា បើអ្នកនិយាយអំពីសំណុំរឿងរបស់អ្នក អ្វីដែលអ្នកនិយាយទាំងអស់ គេអាចយកវាទៅប្រើសម្រាប់ប្រឆាំងចំពោះរូបអ្នក ។

ទីបី គឺអ្នកមានសិទ្ធិមានមេធាវី គ្រប់ដំណាក់កាលទាំងអស់នៃដំណើរការសំណុំរឿងរបស់អ្នក ។ បើអ្នកមិនមានលទ្ធភាពរកប្រាក់បង់ថ្លៃមេធាវីបានទេ ហើយអ្នកកំពុងតែប្រឈមនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្រិតធ្ងន់ ឬបើទំនងអាចត្រូវជាប់គុក អ្នកអាចស្នើសុំមេធាវីដែលតុលាការតែងតាំង ឲ្យធ្វើជាតំណាងរូបអ្នក ដែលអ្នកត្រូវបង់ថ្លៃមេធាវីតិចតួច ឬក៏មិនត្រូវបង់តែម្តង ។ ដើម្បីដាក់ពាក្យសុំមេធាវីដែលតែងតាំងដោយតុលាការ គឺអ្នកត្រូវបំពេញពាក្យសុំ ហើយត្រូវធ្វើការស្បថស្បែថា ព័ត៌មានដែលអ្នកផ្តល់ឲ្យ គឺសុទ្ធតែជាការពិតទាំងអស់ ។ បើអ្នកត្រូវការជំនួយ គឺអ្នកពិនិត្យហិរញ្ញវត្ថុ ឬក៏បុគ្គលិកក្នុងការិយាល័យក្រឡាបញ្ជី អាចជួយអ្នកបាន ។ ទោះជាយ៉ាងណាក៏ដោយ សូមចងចាំទុកថា ក្រឡាបញ្ជីមិនអាចផ្តល់ដំបូន្មានច្បាប់ដល់អ្នកបានឡើយ ។ ចៅក្រម នឹងពិនិត្យមើលឡើងវិញនូវព័ត៌មាន ដែលអ្នកបានផ្តល់ជូនក្រោមការស្បថស្បែ ដើម្បីកំណត់ថាតើអ្នកមានសិទ្ធិអាចទទួលបានមេធាវីដែលតុលាការតែងតាំងដែរឬទេ ។

ទីបួន អ្នកមានសិទ្ធិទទួលបានការកាត់ទោសដោយមានគណៈវិនិច្ឆ័យចូលរួមស្តាប់ ហើយសម្រេចសំណុំរឿងរបស់អ្នក បើអ្នកមិនបានជ្រើសរើសយកវិធីឲ្យចៅក្រម ជាអ្នកសម្រេចក្នុងដំណើរការកាត់ទោសទេនោះ ។ បើថ្ងៃនេះ អ្នកឆ្លើយថាខ្លួនមិនមានកំហុស អ្នកនៅមានឱកាសថ្ងៃក្រោយ ដើម្បីរកដំណោះស្រាយសំណុំរឿងរបស់អ្នក នៅមុនពេលតុលាការចេញកាលវិភាគដើម្បីកាត់ក្តី ។

ជាទីបញ្ចប់ នៅក្នុងសវនាការកាត់ក្តី គឺអ្នកមានសិទ្ធិស្តាប់ និងមើលភស្តុតាងដែលរដ្ឋបានប្រមូល អ្នកក៏មានសិទ្ធិសួរចម្លើយសាក្សីរបស់រដ្ឋ ហើយអ្នកក៏មានសិទ្ធិបង្ហាញសាក្សីរបស់អ្នកផងដែរ ។ អ្នកក៏មានសិទ្ធិធ្វើកសិណសាក្សីក្នុងដំណើរការកាត់ក្តីផងដែរ ។ ឬជាជម្រើស អ្នកក៏មានសិទ្ធិមិនធ្វើកសិណសាក្សីបានដែរ ហើយបើអ្នកសម្រេចមិនធ្វើកសិណសាក្សីនៅក្នុងពេលកាត់ក្តី ការសម្រេចដែលបានធ្វើឡើង គឺគេមិនអាចយកវាមកប្រើប្រឆាំងនឹងរូបអ្នកបានឡើយ ។

**ស៊ូសាន (SUSAN** ៖ សូមអរគុណចំពោះព័ត៌មាននេះ លោកចៅក្រមឌូក្លាស់ (Douglas) ។ ឥឡូវយើងនាំគ្នាមើលពីដំណើរការចោទប្រកាន់ទោស ដែលមានពន្យល់បន្ថែមអំពីសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នក ។

**ការបដិសេធមិនទទួលខុសត្រូវចំពោះអ្វីដែលមាននៅលើអេក្រង់ —** អាស្រ័យលើមូលហេតុដែលអ្នកមកទីនេះ ក្នុងថ្ងៃនេះ នីតិវិធីចំពោះសំណុំរឿងរបស់អ្នក អាចមានភាពខុសគ្នា ។ បើអ្នកមានចម្ងល់អំពីអ្វីមួយ សូមសួរចៅក្រម ឬសុំឲ្យមេធាវីរបស់អ្នកពន្យល់ព័ត៌មានលំអិតជាក់លាក់ដែលត្រូវនឹងសំណុំរឿងរបស់អ្នក មុនពេលអ្នកសម្រេចចិត្ត ឬធ្វើចំណាត់ការអ្វីមួយចំពោះសំណុំរឿងរបស់អ្នក ។

## ភាគទី 2 – បន្ទប់តុលាការដែលមានមនុស្សពេញ

**ប្រធាន** ៖ សូមទាំងអស់គ្នាក្រោកឈរ ។

**តុលាការ** ៖ សូមអរគុណ ឥឡូវអ្នកទាំងអស់គ្នាអាចអង្គុយចុះវិញបាន ។

អរុណសួស្តី ។ គោលបំណងនៃដំណើរការក្នុងថ្ងៃនេះ គឺដើម្បីឱ្យខ្ញុំបានពន្យល់អំពីការចោទប្រកាន់ ដែលគេប្តឹងអំពីអ្នក ដើម្បីណែនាំអ្នកអំពីសិទ្ធិរបស់អ្នក ហើយប្រការដែលសំខាន់ជាងគេគឺការស្នើសុំឱ្យអ្នកផ្តល់ចម្លើយ ឬក៏ឆ្លើយតបចំពោះការចោទប្រកាន់ ។ ក្នុងនេះផងដែរ ខ្ញុំក៏នឹងបញ្ជាក់ប្រាប់អំពីការដាក់ប្រាក់ធានា ឬក៏លក្ខខណ្ឌក្នុងការដោះលែង បើអ្នកត្រូវរងការចោទប្រកាន់ពីបទទោសឧក្រិដ្ឋ ។ ថ្ងៃនេះ មិនមែនជាថ្ងៃដើម្បីកាត់ក្តីចំពោះសំណុំរឿងរបស់អ្នកឡើយ ។ ការកាត់ក្តីចំពោះសំណុំរឿងរបស់អ្នក នឹងកំណត់ឡើងនាពេលខាងមុខ ហើយថ្ងៃនេះយើងនឹងប្រាប់អ្នកពីកាលបរិច្ឆេទនៃការកាត់ក្តី ។

ជារួមគឺមានមូលដ្ឋានគ្រឹះចំនួនពីរក្នុងការចោទប្រកាន់ ៖ គឺការប្រព្រឹត្តល្មើសបទរដ្ឋប្បវេណី និងបទឧក្រិដ្ឋ ។ យើងនឹងប្រាប់អ្នកឱ្យបានដឹង ថាតើការចោទប្រកាន់ចំពោះអ្នក ជាបទឧក្រិដ្ឋ ឬជាបទរដ្ឋប្បវេណី ហើយយើងក៏នឹងប្រាប់អ្នកផងដែរគេចោទប្រកាន់អ្នកអំពីរឿងអ្វី ។ បើអ្នកមកទីនេះ ដោយមានមូលហេតុផ្សេង គឺខ្ញុំនឹងពិភាក្សារឿងនោះជាមួយអ្នក ពេលសំណុំរឿងរបស់អ្នកចូលមកដល់ ។

### <u>ការប្រព្រឹត្តល្មើសបទរដ្ឋប្បវេណី</u>

បើគេចោទប្រកាន់អ្នកអំពីបទល្មើសរដ្ឋប្បវេណី គឺថ្ងៃនេះយើងនឹងសួរអ្នកថាតើអ្នកព្រមទទួលកំហុស ឬបដិសេធការចោទប្រកាន់នេះ ។ ការប្រព្រឹត្តល្មើសបទរដ្ឋប្បវេណី គឺមិនមែនជាបទឧក្រិដ្ឋឡើយ ហើយក៏មិនត្រូវរដាក់ទោសទណ្ឌដោយការជាប់គុកដែរ ។ ទោសទណ្ឌចំពោះការប្រព្រឹត្តល្មើសបទរដ្ឋប្បវេណី មានជាអាទិ៍ ការផាកពិន័យ ការបង់សំណង ការព្យួរអាជ្ញាប័ណ្ណ ឬការជួយការងារសហគមន៍ ។ គ្រប់សំណុំរឿងរដ្ឋប្បវេណីទាំងអស់ គឺគេមានរួមបញ្ចូលនូវថ្លៃបន្ថែម និងថ្លៃផ្សេងៗទៀតក្នុងការផាកនេះដែរ ។

បើអ្នកសម្រេចថាត្រូវឡើងតុលាការ ចំពោះការប្រព្រឹត្តបទល្មើសរដ្ឋប្បវេណី បន្ទុករបស់រដ្ឋក្នុងការបង្ហាញភស្តុតាងនៅក្នុងពេលកាត់ក្តី គឺមានភាពតិចជាងការកាត់ក្តីសំណុំរឿងឧក្រិដ្ឋកម្ម ។ ចំពោះករណីការរំលោភបទរដ្ឋប្បវេណី រដ្ឋត្រូវតែបង្ហាញភស្តុតាងបញ្ជាក់ថា អ្នកបានប្រព្រឹត្តិរំលោភ ដោយការលើកយកភស្តុតាងសំខាន់ៗមកបញ្ជាក់ គឺមានន័យថា ជាភស្តុតាងដែលបង្ហាញថា អ្នកប្រាកដជាបានប្រព្រឹត្តិរំលោភពិតមែន ។

### <u>ការចោទប្រកាន់អំពីបទឧក្រិដ្ឋកម្ម</u>

ក្នុងសំណុំរឿងឧក្រិដ្ឋកម្ម ការកាត់ទោសអាចរួមបញ្ចូលនូវការកាត់ទោសឱ្យជាប់គុក ការផាកពិន័យ ការបង់សំណង ការព្យួរអាជ្ញាប័ណ្ណ និងការព្យួរទោសមានលក្ខខណ្ឌ ការជួយការងារសហគមន៍ ឬការរួមបញ្ចូលគ្នានូវចំណុចទាំងអស់នេះ ។ ក្នុងគ្រប់សំណុំរឿងឧក្រិដ្ឋកម្មទាំងអស់ គឺគេមានរួមបញ្ចូលនូវថ្លៃបន្ថែម និងថ្លៃផ្សេងៗទៀតក្នុងការផាកនេះដែរ ។ ក្នុងករណីមួយចំនួន គឺចាំបាច់ត្រូវតែកាត់ទោសឱ្យជាប់គុក ។ នៅពេលខ្ញុំហៅសំណុំរឿងរបស់អ្នក ខ្ញុំនឹងប្រាប់អ្នកឱ្យដឹងថាតើការចោទប្រកាន់ចំពោះអ្នក អាចតម្រូវឱ្យអ្នកត្រូវជាប់គុកឬទេ ។

សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ

អំពើឧក្រិដ្ឋកម្មគឺគេកំណត់ទៅតាមចំណាត់ថ្នាក់ ហើយក្នុងចំណាត់ថ្នាក់ទោសឧក្រិដ្ឋនីមួយៗ គឺមានបញ្ជាក់អំពីថិរវេលាអតិបរមាចំពោះការជាប់គុក និងចំនួនផាកពិន័យជាអតិបរមា ។ ពេលខ្ញុំហៅសំណុំរឿងរបស់អ្នក ខ្ញុំនឹងប្រាប់អ្នកអំពីថ្នាក់នៃបទឧក្រិដ្ឋ ដែលគេចោទប្រកាន់អ្នក ។

ជាដំបូង ខ្ញុំនឹងប្រាប់អ្នកអំពីទោសឧក្រិដ្ឋថ្នាក់ D និង E ដែលជាញយៗគឺគេនិយាយសំដៅលើបទល្មើសមជ្ឈិម ។

- ទោសឧក្រិដ្ឋថ្នាក់ D គឺអាចត្រូវជាប់គុកជាអតិបរមារហូតដល់ 364 ថ្ងៃ និងការពិន័យជាប្រាក់ជាអតិបរមារហូតដល់ $2,000 ។
- ទោសឧក្រិដ្ឋថ្នាក់ E គឺអាចត្រូវជាប់គុកជាអតិបរមារហូតដល់ 6ខែ និងការពិន័យជាប្រាក់ជាអតិបរមារហូតដល់ $1,000 ។

បើអ្នកត្រូវគេចោទប្រកាន់ពីបទឧក្រិដ្ឋថ្នាក់ D ឬ E គឺយើងនឹងសុំឲ្យអ្នកចូលផ្តល់ចម្លើយក្នុងថ្ងៃនេះតែម្តង ។ អ្នកអាចផ្តល់ចម្លើយថាខ្លួនបានធ្វើខុស ប្រកែកថាខ្លួនមិនបានប្រព្រឹត្តិខុសទេ ឬក៏មិនព្រមឆ្លើយអ្វីទាំងអស់ ។ បើអ្នកផ្តល់ចម្លើយថាខ្លួនបានប្រព្រឹត្តិខុស គឺមានន័យថាអ្នកព្រមទទួលសារភាពថា អ្នកបានប្រព្រឹត្តិបទឧក្រិដ្ឋមែន ហើយតុលាការនឹងដាក់ទោសអ្នកតាមការចោទប្រកាន់ ។ បើអ្នកមិនព្រមឆ្លើយអ្វីទាំងអស់ គឺមានន័យថា អ្នកមិនព្រមទទួលសារភាពថាខ្លួនបានប្រព្រឹត្តិបទឧក្រិដ្ឋនោះទេ តែអ្នកយល់ព្រមថា រដ្ឋអាចមានភស្តុតាងប្រឆាំងនឹងរូបអ្នក ហើយអ្នកក៏យល់ព្រមចំពោះការចោទប្រកាន់ គឺគេរកកំហុសអ្នកឃើញពីការចោទប្រកាន់ ដោយមិនបាច់មានការកាត់ទោស ។

បើអ្នកសារភាពកំហុស ឬមិនព្រមឆ្លើយអ្វីទាំងអស់ គឺតុលាការនឹងដាក់ទោសឧក្រិដ្ឋចំពោះអ្នក ហើយបោះបង់សិទ្ធិទាំងអស់ដែលខ្ញុំបានពន្យល់ប្រាប់អ្នកពីដំបូង ដែលរួមទាំងសិទ្ធិសុំឲ្យមានការកាត់ក្តី ដែលក្នុងករណីនេះគឺរដ្ឋត្រូវតែបង្ហាញភស្តុតាងសមហេតុផល ដែលហួសពីការសង្ស័យថា អ្នកបានប្រព្រឹត្តិបទឧក្រិដ្ឋនោះមែន ។ ការវិនិច្ឆ័យទោសអាចសម្រេចចេញក្នុងថ្ងៃនេះ ។

បើអ្នកត្រូវបានកាត់ទោសឲ្យជាប់ឃាំង ឬជាប់គុក ក្នុងថ្ងៃនេះ គឺអាជ្ញាធរអាចយកអ្នកចូលគុកក្នុងថ្ងៃនេះតែម្តង ឬក៏តុលាការអាចកំណត់ប្រាក់ធានា ឬដាក់លក្ខ័ណ្ឌ ហើយអនុញ្ញាតឲ្យអ្នកមកបង្ហាញខ្លួននៅតុលាការតាមម៉ោង និងកាលបរិច្ឆេទនាពេលក្រោយ ។ បើអ្នកស្នើសុំការពន្យារពេលដាក់ទោស គឺអ្នកត្រូវតែពន្យល់ហេតុផលចំពោះការស្នើសុំនេះទៅកាន់តុលាការ ។

ឥឡូវ ខ្ញុំនឹងប្រាប់អំពីទោសឧក្រិដ្ឋថ្នាក់ A, B និងថ្នាក់ C ដែលជាញយៗគេនិយាយសំដៅលើបទឧក្រិដ្ឋកម្រិតធ្ងន់។

- បទឧក្រិដ្ឋថ្នាក់ A គឺមានការកាត់ទោសឲ្យជាប់គុកជាអតិបរមារហូតដល់ 30 ឆ្នាំ និងការពិន័យជាប្រាក់ជាអតិបរមាររហូតដល់ $50,000 ។
- បទឧក្រិដ្ឋថ្នាក់ B គឺមានការកាត់ទោសឲ្យជាប់គុកជាអតិបររហូតដល់ 10 ឆ្នាំ និងការពិន័យជាប្រាក់អតិបរមារហូតដល់ $20,000 ។
- បទឧក្រិដ្ឋថ្នាក់ C គឺមានការកាត់ទោសឲ្យជាប់គុកជាអតិបរមានរហូតដល់ 5 ឆ្នាំ និងការពិន័យជាប្រាក់អតិបរមាររហូតដល់ $5,000 ។

បើអ្នកត្រូវបានចោទប្រកាន់ពីបណ្តឹងលើបទឧក្រិដ្ឋថ្នាក់ A, B ឬ C គឺអ្នកនឹងមិនត្រូវចូលផ្តល់ចម្លើយក្នុងថ្ងៃនេះទេ ។ នេះគឺដោយសារថា ជាមួយនឹងការចោទប្រកាន់បទឧក្រិដ្ឋកម្រិតធ្ងន់ មុនពេលអ្នកចូលផ្តល់ចម្លើយ ជាបឋម រដ្ឋត្រូវបង្ហាញសំណុំរឿងរបស់ខ្លួនចំពោះអង្គគណៈវិនិច្ឆ័យសិន ដែលពួកគេត្រូវបញ្ជូនត្រឡប់វិញនូវដីការចោទប្រកាន់ បើពួកគេកំណត់ឃើញថា គឺមានភស្តុតាងគ្រប់គ្រាន់ដើម្បីចោទប្រកាន់ចំពោះរូបអ្នក ។ អ្នកអាចសម្រេចលះបង់ ឬបោះបង់សិទ្ធិ ស្នើសុំឲ្យគេយកសំណុំរឿងរបស់អ្នកទៅឲ្យអង្គគណៈវិនិច្ឆ័យពិចារណា និងសារភាពទោសពីបទឧក្រិដ្ឋកម្រិតធ្ងន់ នៅមុនពេលអង្គគណៈវិនិច្ឆ័យចេញដីកាចោទប្រកាន់ ។ តែទោះជាយ៉ាងណាក៏ដោយ គឺអ្នកមិនត្រូវគិតចង់ធ្វើរឿងនេះ ដោយមិនមានការពិភាក្សាជាមួយនឹងមេធាវីឡើយ ។

**<u>មិនមានកំហុស / ដំណើរការនាពេលអនាគត</u>**

បើអ្នកមិនសារភាពទទួលកំហុស ឬបដិសេធការចោទប្រកាន់ក្នុងថ្ងៃនេះ ឬក៏បើអ្នកមកទីនេះ សម្រាប់ជាការបង្ហាញខ្លួនលើកដំបូង ចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋកម្រិតធ្ងន់ ដែលនៅមិនទាន់មានចេញដីការចោទប្រកាន់នៅឡើយ គឺតុលាការនឹងប្រាប់អ្នកពីកាលបរិច្ឆេទមួយចំនួនដែលអ្នកត្រូវមកបង្ហាញខ្លួននៅតុលាការជាបន្តទៀត ។ ក្នុងសំណុំរឿងបទឧក្រិដ្ឋភាគច្រើន កាលបរិច្ឆេទដែលអ្នកត្រូវមកជួបតុលាការបន្ទាប់ គឺដើម្បីការប្រជុំ សម្រេចទោស ។ នេះគឺជាការប្រជុំ រវាងចៅក្រម ជាមួយអ្នក ឬជាមួយមេធាវីរបស់អ្នក និងសភាចាបុរស ដើម្បីចង់ដឹងថាតើអ្នក និងសភាចាបុរស អាចព្រមព្រៀងគ្នាចំពោះវិធីក្នុងការដោះស្រាយសំណុំរឿង ដោយមិនបាច់កាត់ក្តីដែរឬទេ ។

នៅក្នុងពេល ឬនៅមុនពេលប្រជុំសម្រេចទោស សភាចាបុរសអាចនឹងរៀបចំឲ្យអ្នកសារភាពទោស ដែលអ្នកមានសិទ្ធិទទួលយកអ្វីដែលគេបានរៀបចំ ឬមិនទទួលយក។ ក្នុងពេលប្រជុំ អ្នកនឹងមានឱកាសដើម្បីពិភាក្សាក្តីកង្វល់ណាមួយរបស់អ្នកអំពីសំណើដែលរដ្ឋផ្តល់ឲ្យ ឬក៏ធ្វើសំណើដោយខ្លួនឯង បើអ្នក ឬមេធាវីរបស់អ្នក នៅមិនទាន់បានធ្វើដូច្នេះទេនោះ ។ បើអ្នក និងសភាចាបុរស អាចព្រមព្រៀងគ្នាចំពោះដំណោះស្រាយលើសំណុំរឿងរបស់អ្នក ដំណោះស្រាយដែលបានស្នើឡើង នឹងត្រូវយកទៅបង្ហាញដល់ចៅក្រម ឲ្យពិចារណា ។

បើក្នុងពេលប្រជុំនេះ នៅតែមិនអាចរកដំណោះស្រាយចំពោះសំណុំរឿងរបស់អ្នកបានទេ សំណុំរឿងនេះ នឹងស្ថិតនៅរង់ចាំការកាត់ក្តី ដែលនឹងត្រូវធ្វើឡើងទៅតាមកាលបរិច្ឆេទដែលអ្នកនឹងទទួលបានក្នុងថ្ងៃនេះ ។

នៅទីបញ្ចប់ ច្បាប់របស់រដ្ឋ Maine តម្រូវឲ្យតុលាការប្រមូលយកស្នាមម្រាមដៃរបស់បុគ្គលដែលរងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋណាមួយ ។ បើភាពតម្រូវរបស់ច្បាប់នេះ អាចអនុវត្តបានចំពោះសំណុំរឿងរបស់អ្នក គឺខ្ញុំនឹងសុំប្រមូលយកស្នាមម្រាមដៃអ្នក នៅពេលយើងពិនិត្យសំណុំរឿងរបស់អ្នក ។

អញ្ចឹង យើងនឹងចាប់ផ្តើមហៅឈ្មោះសំណុំរឿងទីមួយ ។

## ភាគទី 3 – ការបង្ហាញខ្លួនរបស់ចុងចោទពីរនាក់

**តុលាការ** ៖ រដ្ឋ Maine ប្រឆាំងនឹង ឈ្មោះដូរ៉ូធីហ្គិប្លឺ (Dorothy Gibler) ។ តើអ្នកនាង Gibler មានមកទេ?

**អ្នកនាង Gibler** ៖ ចាស៎! មក ។

**តុលាការ** ៖ សូមចេញមកខាងមុខ ។ គេបានចោទប្រកាន់ថា នៅថ្ងៃទី 10 ខែមករា ឆ្នាំ 2018 គឺពេលអ្នកស្ថិតក្រោមអាយុ 21 ឆ្នាំ ហើយអ្នកមានជាប់ខ្លួននូវគ្រឿងស្រវឹង ពោលគឺស្រាបៀ ចំនួន 6 កំប៉ុង នៅ South Portlandនៃរដ្ឋ Maine ។ នេះជាបទល្មើសរដ្ឋប្បវេណី គឺមិនមែនជាបទឧក្រិដ្ឋឡើយ ។ តើអ្នកមានសំណួរអ្វី ស្តីអំពីសិទ្ធិផ្លូវច្បាប់ ឬការទទួលខុសត្រូវរបស់អ្នកដែរឬទេ?

**អ្នកនាង GIBLER** – អញ្ចឹងបើនាងខ្ញុំ សារភាពកំហុស គឺមានន័យថា នាងខ្ញុំមិនបាច់ជាប់គុកមែនទេ ។

**តុលាការ** ៖ ត្រឹមត្រូវហើយ ។ នេះជាសំណុំរឿងរដ្ឋប្បវេណី គឺមិនមែនជាសំណុំរឿងឧក្រិដ្ឋកម្មឡើយ ដូច្នេះគឺមិនអាចត្រូវជាប់គុកឡើយ ។

**អ្នកនាង GIBLER** ៖ ចាស៎ ។

**តុលាការ** ៖ អញ្ចឹងតើអ្នកផ្តល់ចម្លើយយ៉ាងដូចម្តេច តើអ្នកព្រមទទួលកំហុស ឬក៏បដិសេធការចោទប្រកាន់ក្នុងពាក្យបណ្តឹង?

**អ្នកនាង GIBLER** ៖ អឺ ខ្ញុំគិតថា សារភាពថាខ្ញុំបានប្រព្រឹត្តខុស ។

**តុលាការ** ៖ អ្នកដូចជាមិនប្រាកដក្នុងខ្លួនឡើយ ។ បើទោះបីជាខ្ញុំមិនអាចចាត់តាំងមេធាវីឲ្យអ្នក ដោយសារនេះគឺជាបទល្មើសរដ្ឋប្បវេណីក៏ដោយ ក៏នៅមានមេធាវីប្រចាំថ្ងៃមានវត្តមាននៅទីនេះដែរក្នុងថ្ងៃនេះ គឺអ្នកនាងអាចពិភាក្សាជាមួយមេធាវីនេះបាន ។ តើអ្នកចង់ពិភាក្សាជាមួយមេធាវីសិន មុនការផ្តល់ចម្លើយដែរឬទេ?

**អ្នកនាង GIBLER** ៖ មិនបាច់ទេ ។ យើងអាចបញ្ចប់រឿងនេះបាន ។

**តុលាការ ៖** អញ្ចឹងគឺមានន័យថា អ្នកកំពុងតែសារភាពថា អ្នកបានប្រព្រឹត្តល្មើសបទរដ្ឋប្បវេណីមួយនេះ ដែលគេចោទប្រកាន់ថា ពេលនោះអ្នកនាងមានអាយុ 21 ឆ្នាំ នៅពេលដែលអ្នកនាងមានស្រាបៀរជាប់ខ្លួន ។ តើនេះ ត្រឹមត្រូវទេ?

**អ្នកនាង . GIBLER** ៖ ចាស៎ គឺពិតប្រាកដហើយ លោកចៅក្រម ។

**តុលាការ** ៖ លោកស្រីសភាថា តើនេះជាទោសលើកទីមួយមែនទេ?

**មេធាវីតុលាការមណ្ឌល** ៖ ចាស៎ លោកចៅក្រម ។ យើងសូមផ្តល់អនុសាសន៍ឲ្យផាកពិន័យចំនួន $200 ។

**តុលាការ** ៖ អញ្ចឹងក៏បានដែរ ។ អ្នកនាង GIbler ។ តើមានអ្វីដែលអ្នកនាងចង់និយាយ នៅមុនពេលខ្ញុំដាក់ចេញការសម្រេចក្តីដែរឬទេ?

**អ្នកនាង GIBLER** ៖ នៅពេលនោះ គឺនៅសល់តែបួនថ្ងៃទៀត នាងខ្ញុំ នឹងមានអាយុគ្រប់ 21ឆ្នាំ ។

**តុលាការ** ៖ តាមការស្តាប់មើលទៅឃើញថាការផាកពិន័យក្នុងកម្រិតអប្បរមាគឺសមរម្យហើយ ហើយខ្ញុំនឹងចេញការផាកពិន័យអ្នកនាងចំនួន $200 ។ តើអ្នកនាងអាចបង់ការផាកពិន័យបានក្នុងថ្ងៃនេះទេ?

**អ្នកនាង GIBLER** ៖ ចាស៎ នាងខ្ញុំ អាចបង់ថ្លៃផាកពិន័យបានក្នុងថ្ងៃនេះតែម្តង ។

**តុលាការ ៖** ល្អ ។ អញ្ចឹងសូមអ្នកនាងរកកន្លែងអង្គុយរង់ចាំ ការរៀបចំសំណុំឯកសាររបស់អ្នកនាងឱ្យបានរួចរាល់សិន ។ អ្នកនាងអាចទៅកាន់ការិយាល័យក្រឡាបញ្ជី ដើម្បីបង់ការផាកពិន័យនេះ និងថ្លៃបន្ថែម បន្ទាប់មកអ្នកនាងអាចទៅផ្ទះវិញបាន ។ នាងខ្ញុំ សូមអរគុណ លោកចៅក្រម ។

**តុលាការ** ៖ សំណុំរឿងបន្ទាប់ គឺជាសំណុំរឿងដែលជាបណ្ដឹងរបស់រដ្ឋ Maine ប្រឆាំងនឹងលោក វីលៀម ប្រោន (William Brown) ។ លោក Brown សូមមេត្តាចេញមកខាងមុខ ។

លោក Brown តុលាការសូមចោទប្រកាន់លោកពីបទល្មើស ប្រើប្រាស់គ្រឿងយន្ត ក្រោមអំណាចគ្រឿងស្រវឹង ជាបទល្មើសទីបី ។ គេបានចោទប្រកាន់លោកថា នៅថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2017 នៅឯ Raymond លោកបានដំណើរការយានយន្ត ក្នុងពេលដែលលោកកំពុងស្រវឹងស្រា ឬថ្នាំញៀន ក្នុងពេលដែលពិនិត្យ បានរកឃើញថា គឺមានជាតិស្រវឹងក្នុងឈាមរបស់លោក ចំនួន .08 ភាគរយ ឬច្រើន ជាងនេះ ។ លោក Brown តើលោកមានមេធាវីទេ?

**លោក BROWN** ៖ ទេ ខ្ញុំបាទមិនមានមេធាវីទេ លោកស្រី ។ បច្ចុប្បន្ន ខ្ញុំបាទអត់ការធ្វើ ហើយស្ទើរតែគ្មានលទ្ធភាពក្នុងការចិញ្ចឹមកូន តើខ្ញុំបាទអាចមានប្រាក់ឯណាទៅជួលមេធាវីនោះ ។

**តុលាការ** ៖ លោក Brown គឺមានន័យថា លោកកំពុងស្នើសុំឱ្យតុលាការ រកមេធាវីម្នាក់ឱ្យលោកមែនទេ?

**លោក BROWN** ៖ បាទ ប្រាកដណាស់ អ្នកស្រីចៅក្រម ។

**តុលាការ** ៖ តើលោកមានបានបំពេញលិខិតថ្លែងសច្ចាដែលបានប្រគល់ជូនលោកមុននេះ ដើម្បីឱ្យតុលាការរកស្មាក្ដី ហើយឬនៅ?

**លោក BROWN** ៖ បាទ! ខ្ញុំបាទ បានបំពេញរួចហើយ អ្នកស្រីចៅក្រម ។ នេះជាលិខិតដែលខ្ញុំបាទបានបំពេញរួចរាល់ ។

**តុលាការ ៖** ល្អ ។ ឱ្យខ្ញុំសូមមើលបន្តិច ។

ក្រោយពេលពិនិត្យមើល លិខិតថ្លែងសច្ចារបស់លោករួចហើយ ខ្ញុំបានដឹងថា គឺលោកពិតជាមិនមានលទ្ធភាពអាចជួលមេធាវីបានឡើយ ដូច្នេះ ខ្ញុំនឹងចាត់តាំងមេធាវី ឱ្យធ្វើជាតំណាងរបស់លោក ។ តើរដ្ឋ មានចង់ឱ្យតុលាការ ពិនិត្យមើលស្ថានភាពការដាក់ប្រាក់ធានាចំពោះករណីលោកប្រោនដែរឬទេ?

**មេធាវីតុលាការមណ្ឌល** ៖ អត់ទេ! លោកស្រីចៅក្រម ។ ស្ថានភាពការដាក់ប្រាក់ធានារបស់គាត់ គឺមានភាពអាចទទួលយកបាន ។

**តុលាការ** ៖ សូមអរគុណ ។ លោក Brown តើលោកមានអ្វីជំទាស់ ចំពោះការដាក់ប្រាក់ធានាបច្ចុប្បន្ន ដែលកំពុងស្ថិតនៅជាធរមានដែរឬទេ?

**លោក BROWN** ៖ ទេ! ខ្ញុំបាទមិនមានអ្វីជំទាស់ទេ លោកស្រីចៅក្រម ។

**តុលាការ** ៖ តើលោកមានសំណួរអ្វីអំពីសិទ្ធិផ្លូវច្បាប់ និងការទទួលខុសត្រូវរបស់លោកដែរឬទេ?

**លោក BROWN** ៖ ទេ! មិនមានទេ លោកស្រីចៅក្រម ។

**តុលាការ** ៖ ប្រធានអង្គពិធី កំពុងតែប្រគល់ក្រដាសមួយសន្លឹកឱ្យលោក ដែលមានបញ្ជាក់អំពីកាលបរិច្ឆេទ សម្រាប់ដំណើរការតុលាការជាបន្តទៅមុខទៀត ។ កាលបរិច្ឆេទទាំងអស់នោះ គឺសម្រាប់ការប្រជុំសម្រេចទោស កាលបរិច្ឆេទដាក់ញត្តិ និងកាលបរិច្ឆេទកាត់ទោស ។ នៅក្នុងលិខិតនោះ ក៏មានផ្តល់ជូននូវព័ត៌មាន ឈ្មោះ និងព័ត៌មានសម្រាប់ទំនាក់ទំនង ពាក់ព័ន្ធនឹងមេធាវីរបស់លោក ផងដែរ ។ វាគឺជាការទទួលខុសត្រូវរបស់លោក ក្នុងការទាក់ទងជាមួយនឹងមេធាវី ហើយត្រូវតែទាក់ទងគាត់ជាបន្ទាន់ ។ ឥឡូវលោកអាចទៅផ្ទះវិញបាន តែជាថ្មីម្តងទៀត សូមកុំភ្លេចទាក់ទងជាមួយនឹងមេធាវីរបស់លោក ឱ្យបានឆាប់ ។

**លោក BROWN** ៖ បាទ អ្នកស្រីចៅក្រម ។ សូមអរគុណ ។

## ភាគទី 4 – បន្ទប់កាត់ក្តីដែលមិនទាន់មានមនុស្សមកដល់

**ស៊ូសាន (SUSAN)**: នាងខ្ញុំត្រឡប់មកវិញហើយ ដោយមានចៅក្រមដូក្លាស់ (Douglas) មកជាមួយផង ។ យើងបានពិភាក្សាគ្នានូវសាច់រឿងជាច្រើន តែក៏នៅមានចំណុចពីរបីទៀត ដែលនាងខ្ញុំចង់សាកសួរបន្ថែម ។ ជាដំបូង តើអ្វីជាប្រយោជន៍ពីការនិយាយជាមួយមេធាវី មុនពេលអ្នកសម្រេចផ្តល់ចម្លើយ?

**តុលាការ** ៖ ច្បាប់ និងបទបញ្ញត្តិរបស់វា អាចមានភាពស្មុគស្មាញបន្តិច ហើយគេត្រូវយកវាមកអនុវត្តចំពោះមនុស្សឱ្យបានស្មើៗគ្នា ។ ចំពោះមនុស្សដែលមិនចេះច្បាប់ គឺអាចមានភាពលំបាកក្នុងការធ្វើជាតំណាងសម្រាប់ខ្លួនឯងនៅក្នុងតុលាការ ។ រដ្ឋ នឹងមានមេធាវីជាអ្នកតំណាងមកពីការិយាល័យមេធាវីរបស់តុលាការមណ្ឌល ។ តាមដែលអាចធ្វើទៅបាន ចំពោះបុគ្គលដែលកំពុងប្រឈមនឹងការចោទប្រកាន់ពីរដ្ឋ ត្រូវមានមេធាវី ឬយ៉ាងហោចណាស់បាននិយាយជាមួយមេធាវី ដើម្បីកំណត់រកមើលវិធីប្រសើរបំផុតក្នុងការទប់ទល់ជាមួយនឹងការចោទប្រកាន់ដែលខ្លួនកំពុងប្រឈម នេះក៏ដោយសារថា អង្គចៅក្រមមិនអាចផ្តល់ជំនួយ ឬដំបូន្មានផ្នែកច្បាប់ដល់អ្នកបានឡើយ ។

**ស៊ូសាន (SUSAN)** ៖ នៅក្នុងរដ្ឋ Maine យើង មានអ្នកបរបាញ់ច្រើនណាស់ ។ តើការកាត់ទោសមានឥទ្ធិពលអ្វី លើលទ្ធភាពនៃការទិញ ឬការមានកាំភ្លើងជារបស់កម្មសិទ្ធិ?

**តុលាការ** ៖ បើអ្នកត្រូវបានកាត់ទោសពីបទឧក្រិដ្ឋណាមួយ គឺអ្នកអាចបាត់បង់សិទ្ធិក្នុងការទិញ មានជាប់ខ្លួន ឬមានកម្មសិទ្ធិចំពោះអាវុធធុនតូច ឬគ្រាប់រំសេវគ្រប់ប្រភេទ ។ បើការមានអាវុធធុនតូចជាកម្មសិទ្ធិ គឺសំខាន់ចំពោះអ្នក អ្នកត្រូវសួរចៅក្រមថាតើ ការចោទប្រកាន់ដែលអ្នកកំពុងប្រឈម អាចបណ្តាលឱ្យអ្នកបាត់បង់សិទ្ធិនេះឬទេ ហើយអ្នកត្រូវពិភាក្សាជាមួយមេធាវី នៅមុនពេលសារភាពទោសកំហុស ឬមិនផ្តល់ចម្លើយ ។

**ស៊ូសាន (SUSAN)** ៖ ជាចុងបញ្ចប់ សូមនិយាយអំពីការផាកពិន័យ ។ តើលោកអាចជួយពន្យល់បានទេថា តើត្រូវបង់ថ្លៃផាកពិន័យ នៅពេលណា ហើយតើនឹងមានអ្វីកើតឡើង បើអ្នកមិនព្រមបង់ថ្លៃផាកពិន័យតាមការកំណត់ទេនោះ?

សម្រាប់តែគោលបំណងព័ត៌មានប៉ុណ្ណោះ

**តុលាការ** ៖ តុលាការរំពឹងថា ថ្លៃផាកពិន័យ ព្រមទាំងថ្លៃបន្ថែម ឬថ្លៃការប៉ាន់ប្រមាណណាមួយ ត្រូវបង់ជូនក្នុងតម្លៃពេញ នៅក្នុងថ្ងៃដែលតុលាការបានកំណត់ចេញមក ។ បើអ្នកពិតជាមិនមានលទ្ធភាពបង់ថ្លៃផាកពិន័យនេះបានពេញថ្លៃ ក្នុងថ្ងៃដែលតុលាការចេញការកំណត់ឱ្យបង់ទេ សូមប្រាប់តុលាការឱ្យបានដឹង ដើម្បីឱ្យតុលាការអាចរៀបចំផែនការសម្រាប់ឱ្យអ្នកអាចបង់ប្រាក់ពិន័យនេះបាន ។ បើអ្នកខកខានមិនបានបង់ប្រាក់ពិន័យតាមការកំណត់ទេនោះ ហើយក៏ខកខានមកបង្ហាញខ្លួននៅពីមុខតុលាការ យើងអាចនឹងចេញដីការចាប់ខ្លួនអ្នក ហើយអាជ្ញាប័ណ្ណរបស់អ្នកដែលចេញដោយរដ្ឋ Maine អាចនឹងត្រូវព្យួរទុកទាំងអស់ ដោយត្រង់នេះ គឺរួមទាំងប័ណ្ណបើកបរផងដែរ ។

**ស៊ូសាន (SUSAN)** ៖ ស្តាប់មើលទៅគឺពិតជាសំខាន់ណាស់ដែលត្រូវបង់ថ្លៃផាកពិន័យឱ្យបានទាន់ពេល ឬត្រូវត្រឡប់មកជួបតុលាការវិញដើម្បីបញ្ជាក់ប្រាប់ពីមូលហេតុដែលអ្នកមិនអាចបង់ប្រាក់នេះឱ្យទាន់ពេលវេលា ។

**តុលាការ** ៖ ត្រឹមត្រូវ ។

**ស៊ូសាន (SUSAN)** ៖ សូមអរគុណច្រើន លោកចៅក្រមដូក្លាស់ (Douglas) ។

**តុលាការ** ៖ អរគុណ Susan ។

## ភាគទី 5 – ចៅក្រម វូដម៉ែន (Woodman) និយាយដាក់កាមេរ៉ា

**តុលាការ** ៖ អ្នកមកបង្ហាញមុខនៅតុលាការ ដោយមានសិទ្ធិសំខាន់ជាប់ខ្លួន ដែលធានាដោយច្បាប់នានា និងច្បាប់រដ្ឋធម្មនុញ្ញរបស់សហរដ្ឋអាមេរិក និងច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋ Maine ។ បើទោះបីជាចៅក្រមអាចប្រាប់អ្នកពីគោលការណ៍ណែនាំ និងធ្វើការបំភ្លឺអំពីសិទ្ធិទាំងអស់នេះខ្លះៗក៏ដោយ ក៏ចៅក្រមមិនអាចតំណាងឱ្យអ្នកដូចជាមេធាវីរបស់អ្នកបានឡើយ ហើយក៏មិនអាចប្រាប់អ្នកបានពីអ្វីដែលអ្នកត្រូវធ្វើតទៅទៀតបានដែរ ។ ជាថ្មីម្តងទៀត អ្នកត្រូវពិភាក្សាជាមួយនឹងមេធាវី បើអ្នកមានសំណួរ ឬកង្វល់អ្វីមួយនោះ ។

ពេលអ្នកទៅជួបក្រឡាបញ្ជី សូមចាំទុកថា ក្រឡាបញ្ជីមិនមែនជាអ្នកដាក់លិខិតចោទប្រកាន់អ្នក ឬក៏ជាអ្នករៀបចំការកាត់ទោសអ្នកដែរ ក្រឡាបញ្ជីគឺគ្រាន់តែជាអ្នកធ្វើការក្នុងការបំពេញសំណុំបែបបទ ចំពោះសំណុំរឿងរបស់អ្នកតែប៉ុណ្ណោះ ។ សូមមេត្តាផ្តល់ការគោរពចំពោះក្រឡាបញ្ជី ដូចអ្វីដែលគេគោរពអ្នកដែរ ។ សូមអរគុណ ។ តុលាការដល់ម៉ោងសម្រាក ។

**ប្រធាន** ៖ សូមអ្នកទាំងអស់គ្នាក្រោកឈរ ។

សម្រាប់តែព័ត៌មានប៉ុណ្ណោះ ។